**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៦៣៧ ......សហវ......

ថ្ងៃ ចន្ទ ១ រោច ខែ ចេត្រ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២១

## ជម្រាបជូន

## ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**កម្មវត្ថុ៖** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍បង្កើនថ្លៃរបបអាហារសិស្សប្រចាំថ្ងៃ របស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់អនុវត្តកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍។

**យោង៖** លិខិតលេខ ៥២៦ អយក.បស ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាបថា បន្ទាប់ពីបានពិនិត្យលើសំណើសុំខាងលើរួចមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តល់ការឯកភាពជាគោលការណ៍លើការបង្កើនថ្លៃរបបអាហារសិស្សប្រចាំថ្ងៃ សម្រាប់អនុវត្តកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តដូចខាងក្រោម៖

១). បង្កើនថ្លៃរបបអាហារពី ៧២០ រៀល/នាក់ ទៅ ៧៨០ រៀល/នាក់ សម្រាប់អាហារពេលព្រឹក, និងបង្កើនពី ១ ២០០ រៀល/នាក់ ទៅ ១ ២៦០ រៀល/នាក់ សម្រាប់របបអាហារពេលថ្ងៃត្រង់ ដោយត្រូវអនុវត្តចាប់ពីឆ្នាំសិក្សា ២០២០-២០២១ នេះតទៅ

២). សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ នេះ, ក្រសួងអប់រំ យុវជន និងកីឡា ត្រូវប្រើប្រាស់ឥណទានថវិកាឆ្នាំ ២០២១ ដែលមានស្រាប់ ចំនួន ៧ ០៧២,៦ លានរៀល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666